សូមដាក់ពាក្យឥឡូវនេះ!

# កម្មវិធីជំនួយសម្រាប់យុវជន ClimateLB

**យើងនឹងផ្តល់ថវិកាជំនួយចំនួន ៥,០០០ ដុល្លារ ដល់ក្រុមយុវជនអាយុចាប់ពី ១៥ ដល់ ២៤ ឆ្នាំ សម្រាប់អនុវត្តគម្រោងសកម្មភាពបអាកាសធាតុ តំបន់ខាងលិចក្រុងឡុងប៊ិច!**



គម្រោងដាំដើមឈើឡើងវិញ



កិច្ចខិតខំប្រឹងប្រែងអប់រំ



កម្មវិធីឯកអគ្គរដ្ឋទូត




យុទ្ធនាការសិល្បៈសាធារណៈ

YOUTH CLIMATE ACTION FUND
Supported by Bloomberg Philanthropies

LONGBEACH
Office of Climate Action & Sustainability

**ដាក់ពាក្យត្រឹមថ្ងៃទី 3/17/2025: lbcity.info/climatelb**

## កម្មវិធីផ្តល់មូលនិធិខ្នាតតូច ឬ ClimateLB សម្រាប់សកម្មភាពអាកាសធាតុក្រុមយុវជន

កម្មវិធីផ្តល់មូលនិធិខ្នាតតូច ឬ ClimateLB សម្រាប់សកម្មភាពអាកាសធាតុក្រុមយុវជននេះ គឺមានបំណងជួយឧបត្ថម្ភគាំទ្រដល់ក្រុមយុវជនអាយុចាប់ពី ១៥-២៤ ឆ្នាំ ដើម្បីយកទៅចំណាយលើការរចនា ផលិត និង រកមើលដំណោះស្រាយបន្ទាន់ខាងអាកាសធាតុ ដើម្បីជួយសាលាក្រុង ឡុងប៊ិចក្នុងការសម្រេចគោលដៅអាកាសធាតុ។ អ្នកពាក្យសុំដែលបំពេញគ្រប់លក្ខខណ្ឌចំនួនដប់ប្រាំពីរនាក់នឹងទទួលបានថវិកាជំនួយចំនួន ៥,០០០ ដុល្លារ ក្នុងមួយនាក់ ដើម្បីយកទៅអនុវត្តគម្រោងយកចិត្តទុកដាក់លើអាកាសធាតុឲ្យមានចីរភាព នៅតំបន់ភាគខាងលិចក្រុងឡុងប៊ិច។

រយៈពេលបើកទទួលពាក្យ នឹងចាប់ផ្តើមពីថ្ងៃសុក្រ ទី២១ ខែកុម្ភៈ ឆ្នាំ២០២៥ ដល់ថ្ងៃចន្ទ ទី១៧ ខែមីនា ឆ្នាំ២០២៥។ ពាក្យសុំនោះនឹងមាននៅតាមអនឡាញ (lbcity.info/climatelb)។ បងប្អូនដែលមានសំណួរជុំវិញរឿងនេះ សូមសរសេរអ៊ីម៉េលទៅកាន់៖ climateaction@longbeach.gov។

### 1. នរណាខ្លះអាចដាក់ពាក្យបាន?

គម្រោងត្រូវតែត្រូវបានស្នើឡើងដោយយុវជនដែលមានអាយុពី ១៥-២៤ ឆ្នាំ។ អង្គការនៅក្នុងទីក្រុងឡុងប៊ិចដែលដឹកនាំដោយយុវជន និងបម្រើយុវជនមានសិទ្ធិដាក់ពាក្យ។ អង្គការដទៃទៀតនៅទីក្រុងឡុងប៊ិចដែរក៏អាចដាក់ពាក្យបានដែរ ឲ្យតែពួកគេសហការគ្នាជាដៃគូជាមួយអង្គការបម្រើយុវជននៅមូលដ្ឋាន ឬពលរដ្ឋក្រុងឡុងប៊ិចទាំងអស់ ដែលមានអាយុចាប់ពី ១៥-២៤ ឆ្នាំ។ ឧទាហរណ៍ អង្គការសង្គមស៊ីវិលផ្នែកអាកាសធាតុ ឬសិល្បៈក៏អាចដាក់ពាក្យបានដែរ ឲ្យតែពួកគេសហការជាដៃគូគ្នាជាមួយក្រុមដែលបម្រើយុវជន និងគម្រោងដែលដឹកនាំដោយយុវជន។

2. **តើថវិកាជំនួយនេះផ្តល់ជូនប៉ុន្មាននាក់?**

ថវិកាជំនួយនេះមានសម្រាប់អ្នកពាក្យដប់ប្រាំពីរនាក់ ដោយម្នាក់ៗនឹងទទួលបាន ៥,០០០ ដុល្លារ ដើម្បីយកទៅគាំទ្រគម្រោងដែលបំពេញគ្រប់លក្ខខណ្ឌ ក្នុងការទទួលបានជំនួយនេះ។

3. **តើគម្រោងបែបណាខ្លះទើបគ្រប់លក្ខខណ្ឌក្នុងការដាក់ពាក្យនេះ?**

កម្មវិធីនេះនឹងផ្តល់អាទិភាពដល់ពាក្យសុំពីអង្គការដែលបម្រើយុវជន ដែលយកចិត្តទុកដាក់លើការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការអនុវត្តសកម្មភាពទាំងនេះនៅតំបន់ភាគខាងលិចក្រុងឡុងប៊ិច និងប្រើសម្រាប់សកម្មភាពយុត្តិធម៌បរិស្ថាន និងសមធម៌ និងត្រូវវិនិយោគលើយុវជន និងសេដ្ឋកិច្ចបៃតង។ អ្នកដាក់ពាក្យមានជាអាទិ៍៖

- **គម្រោងដឹកនាំដោយយុវជនដើម្បីបង្កើតព្រៃ និងដាំដើមឈើឡើងវិញ៖** គម្រោងដែលប្រើប្រាស់យុវជនស្ម័គ្រចិត្ត ដើម្បីដាំដើមឈើ កែលម្អទីធ្លាបៃតងក្នុងទីក្រុង និងបង្កើនម្លប់ដើមឈើនៅតំបន់ទីក្រុង ដើម្បីឲ្យមានខ្យល់អាកាសល្អប្រសើរ និងភាពធន់នឹងអាកាសធាតុជាងមុន។
- **គម្រោងអប់រំអំពីអាកាសធាតុដែលដឹកនាំដោយយុវជន៖** គម្រោងអប់រំនេះគឺត្រូវតែដឹកនាំដោយយុវជន ដែលយកចិត្តទុកដាក់លើសាលារៀន និងសហគមន៍ក្នុងមូលដ្ឋាន ដើម្បីបង្កើនការដឹង និងយល់ដឹងអំពីបញ្ហាអាកាសធាតុ។
- **កម្មវិធីទូតយុវជនអាកាសធាតុ៖** កម្មវិធីដែលឲ្យយុវជនបានចូលរួមក្នុងការផ្តល់ព័ត៌មានអំពីអាកាសធាតុក្នុងមូលដ្ឋាន និងធនធានបរិស្ថាន ឲ្យបានលឺដល់អាជីវកម្ម អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន។
- **យុទ្ធនាការសិល្បៈសាធារណៈដែលជាស្នាដៃយុវជន និងការលើកកម្ពស់ការយល់ដឹង៖** ភាពជាដៃគូគ្នាជាមួយវិចិត្រករជាយុវជន ដើម្បីដំឡើងស្នាដៃសិល្បៈសាធារណៈ និងបើកយុទ្ធនាការលើកកម្ពស់ការយល់ដឹងដែលបញ្ចូលសារឲ្យសាធារណជនទូទៅដឹងអំពី

ភាពបន្ទាន់នៃសកម្មភាពអាកាសធាតុ និងគោលដៅអាកាសធាតុរបស់សាលាក្រុង។

4. **តើខ្ញុំដាក់ពាក្យដោយរបៀបណា?**

ពាក្យសុំនឹងបើកឲ្យដាក់នៅតាមគេហទំព័រនេះ ចាប់ពី**ថ្ងៃសុក្រ ទី២១ ខែកុម្ភៈ ឆ្នាំ២០២៥** និងឈប់ទទួលបានត្រឹមម៉ោង ១១:៥៩ ថ្ងៃត្រង់ នៅ**ថ្ងៃចន្ទ ទី១៧ ខែមីនា ឆ្នាំ២០២៥។** យើងមានផ្តល់ជំនួយបច្ចេកទេស ដើម្បីជួយអ្នកដាក់ពាក្យក្នុងការដាក់ពាក្យ។

5. **តើសាលាក្រុងសម្រេចជ្រើសរើសបេក្ខជនដាក់ពាក្យ និងឯកភាពលើពាក្យសុំនោះដោយរបៀបណា និងធ្វើអង្កាល់?**

យើងនឹងបិទលែងទទួលពាក្យសុំនៅម៉ោង **១១:៥៩ ថ្ងៃត្រង់** នៅថ្ងៃទី **១២ ថ្ងៃចន្ទ ទី១៧ ខែមីនា ឆ្នាំ២០២៥។** ការិយាល័យសកម្មភាពអាកាសធាតុ នឹងពិនិត្យមើលពាក្យសុំនោះ ដើម្បី រកមើលថាតើអ្នកដាក់ពាក្យបំពេញគ្រប់លក្ខខណ្ឌអប្បបរមានៃកម្មវិធីនេះដែរឬយ៉ាងណាសិន។ អ្នកដាក់ពាក្យដែលមិនបំពេញគ្រប់លក្ខខណ្ឌអប្បបរមាននេះ នឹងត្រូវបានជូនដំណឹងត្រឹមថ្ងៃទី **ថ្ងៃចន្ទ ទី២៤ ខែមីនា ឆ្នាំ២០២៥។** គណៈកម្មាការជ្រើសរើសនឹងពិនិត្យឡើងវិញនូវពាក្យសុំ ហើយបេក្ខជនដែលទទួលបានជោគជ័យនឹងត្រូវបានជូនដំណឹងត្រឹម ដើមខែមេសា។

6. **តើអង្កាល់ទើបថវិកាជំនួយនោះនឹងត្រូវប្រគល់ ?**

មូលនិធិនេះនឹងត្រូវប្រគល់ជូនអ្នកជាប់ ត្រឹមថ្ងៃទី **ថ្ងៃសុក្រ ទី៩ ខែឧសភា ឆ្នាំ២០២៥** ហើយទឹកប្រាក់ ៥,០០០ ដុល្លារទាំងស្រុងនោះ នឹងត្រូវប្រើប្រាស់ឲ្យអស់ត្រឹមថ្ងៃទី **ថ្ងៃសុក្រ ទី៣១ ខែតុលា ឆ្នាំ២០២៥។**

7. **តើនរណាជាម្ចាស់លុយ?**

មូលនិធិ Youth Climate Action Fund នេះឧបត្ថម្ភដោយក្រុមហ៊ុនធំ Bloomberg Philanthropies ដែលសហការជាដៃគូគ្នាជាមួយ United Cities និងរដ្ឋាភិបាលមូលដ្ឋាន និងមជ្ឈមណ្ឌល Bloomberg Center for Public Innovation នៃសកលវិទ្យាល័យ Johns Hopkins និងចាត់ចែងដោយក្រុមប្រឹក្សា Rockefeller Philanthropy Advisor